# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤១ ក.ក៦

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង សម្រាប់រៀបចំពិធីប្រារព្ធខួប២៥ឆ្នាំ នៃការបង្កើតអាជ្ញាធរជាតិអប្សរា រួមគ្នាជាមួយនឹងព្រឹត្តិការណ៍ The Cambodian Magic Flute នៅរមណីយដ្ឋានអង្គរ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៧/៣១៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការផ្ទេរអាជ្ញាធរ គណៈកម្មាធិការ និងក្រុមប្រឹក្សាដែលស្ថិតនៅក្រោមសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យស្ថិតនៅក្រោមសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ
- បានឃើញអនុក្រឹត្យលេខ ២៤អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង សម្រាប់រៀបចំពិធីប្រារព្ធខួប២៥ឆ្នាំនៃការបង្កើតអាជ្ញាធរជាតិអប្សរា រួមគ្នាជាមួយនឹងព្រឹត្តិការណ៍ The Cambodian Magic Flute ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ នៅរមណីយដ្ឋានអង្គរ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ប្រធាន |
| ២- តំណាងក្រសួងព្រះបរមរាជវាំង | អនុប្រធាន |
| ៣- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤- តំណាងក្រសួងមហាផ្ទៃ | សមាជិក |

៥- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
៦- តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
៧- តំណាងក្រសួងទេសចរណ៍ សមាជិក
៨- តំណាងក្រសួងបរិស្ថាន សមាជិក
៩- តំណាងក្រសួងព័ត៌មាន សមាជិក
១០- តំណាងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ សមាជិក
១១- អភិបាលនៃគណៈអភិបាលខេត្តសៀមរាប សមាជិក
១២- អគ្គនាយកអាជ្ញាធរជាតិអប្សរា សមាជិកអចិន្ត្រៃយ៍

**ប្រការ២ .-**

គណៈកម្មការអន្តរក្រសួងនេះមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ ចាត់ចែង ត្រួតពិនិត្យ សម្របសម្រួលជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរដែនដី
- រៀបចំខ្លឹមសារ ឯកសារ លិខិតបទដ្ឋានរដ្ឋបាល បដាពាក្យស្លោក និងការងារពាក់ព័ន្ធសម្រាប់ពិធី
- រៀបចំគម្រោងចំណាយនៃកិច្ចដំណើរការពិធី
- ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសង្គ្រោះបន្ទាន់
- ទំនាក់ទំនង និងសហការជាមួយអាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធក្នុងការអញ្ជើញភ្ញៀវ
- អនុវត្តភារកិច្ចផ្សេងៗទៀតទៅតាមការចាំបាច់ និងការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**ប្រការ៣ .-**

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារបន្ថែមតាមការចាំបាច់។

**ប្រការ៤ .-**

សេចក្តីសម្រេចលេខ១៧១ សសរ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សម្រាប់រៀបចំពិធីប្រារព្ធខួប២៥ឆ្នាំនៃការបង្កើតអាជ្ញាធរជាតិអប្សរា រួមគ្នាជាមួយនឹងព្រឹត្តការណ៍ Cambodian Magic Flute នៅមេណីយដ្ឋានអង្គរ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ